អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញា

ព័ត៌មាន និងគំនិតយោបល់ផ្សេងៗពីបណ្តាជនរងគ្រោះ និងអង្គការសង្គមស៊ីវិលនានា បានធ្វើឱ្យមានការដាក់ជូននូវសេចក្តីសន្និដ្ឋានបន្ថែម ធ្វើឡើងដោយសហព្រះរាជអាជ្ញានៃ អ.វ.ត.ក ដោយអំពាវនាវឱ្យមានការស៊ើបសួរថ្មីៗទៅលើបទឧក្រិដ្ឋនៃរបបខ្មែរក្រហមបន្ថែមទៀត ។ សហព្រះរាជអាជ្ញានៃ អ.វ.ត.ក បានស្នើកាលពីថ្ងៃពុធថា សហចៅក្រមស៊ើបអង្កេត បើកការស៊ើបសួរទៅលើការចោទប្រកាន់នៃបទឧក្រិដ្ឋនានាដែលបានប្រព្រឹត្តិ នៅឯមណ្ឌលសន្តិសុខមួយរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ជាទីកន្លែងដែលមានពលរដ្ឋកម្ពុជាជាច្រើននាក់ត្រូវបានគេឃុំខ្លួនដោយខុសច្បាប់ ទទួលរងនូវស្ថានភាពអមនុស្សធម៌ និងការងារដោយបង្ខំ អំពើទារុណកម្ម និងការកាប់សម្លាប់ នៅរវាងចន្លោះ ឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ។ “ការចោទប្រកាន់ជាក់ស្តែងទាំងនេះ ប្រសិនបើរកឃើញ អាចនឹងរួមបង្កើតបានជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងការរំលោភទៅលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលត្រូវផ្តន្ទាទោសនៅក្រោមច្បាប់ អ.វ.ត.ក ហើយយើងក៏បានធ្វើការចោទប្រកាន់ដូច្នេះរួចហើយដែរនៅក្នុងសេចក្តីសន្និដ្ឋានរបស់យើង” នេះបើតាមប្រសាសន៍របស់សហព្រះរាជអាជ្ញា លោក Robert PETIT ។

សហព្រះរាជអាជ្ញា បានស្នើបន្ថែមទៀតថា ជនត្រូវចោទ **នួន ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធ** និង **កាំង ហ្គេចអ៊ាវ** ដែលក្នុងពេលបច្ចុប្បន្ន អ្នកទាំងនេះបាននឹងកំពុងស្ថិតនៅក្រោមការឃុំខ្លួនរបស់ អ.វ.ត.ក ត្រូវមានការស៊ើបសួរអំពីការចូលរួមពាក់ព័ន្ធរបស់ពួកគេនៅក្នុងបទឧក្រិដ្ឋទាំងនេះ ។ មិនមានជនសង្ស័យបន្ថែមទៀតឡើយដែលត្រូវបានកំណត់នៅក្នុងសេចក្តីសន្និដ្ឋានបន្ថែម ។ លោក Petit បានមានប្រសាសន៍ថា “សេចក្តីសន្និដ្ឋាននេះ បន្ថែមពីលើសំណើពីលើកមុនដែលបានស្នើឱ្យសហចៅក្រមស៊ើបអង្កេត ធ្វើការស៊ើបសួរទៅលើស្ថានភាពពិតប្រាកដចំនួន ២៥ មានចរិតស្រដៀងៗគ្នា ដែលបានកើតឡើងនៅក្នុងអំឡុងពេលនៃសម័យកាលនៃកម្ពុជាប្រជាធិបតេយ្យ” ។ សំណើពីដំបូងនោះ គឺជា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីមួយរបស់សហព្រះរាជអាជ្ញា ត្រូវបានបញ្ជូនកាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ។

សំណើនេះ បានដាក់អមទៅជាមួយនូវឯកសារគាំទ្រជាង៣០ ដែលរួមបញ្ចូលគ្នាមានប្រហែល ១,៥០០ទំព័រនៃរបាយការណ៍វិភាគ កំណត់ហេតុនៃបទសម្ភាសន៍សាក្សី និងឯកសារផ្សេងៗទៀត នៅក្នុងសម័យកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ភាគច្រើននៃភស្តុតាងទាំងនេះ បានប្រមូលដោយមានជំនួយពី មជ្ឈមណ្ឌល

ឯកសារកម្ពុជា ។ "ជាសំខាន់ សំណើនេះត្រូវបានបញ្ជូនដោយសារមានការផ្តល់ព័ត៌មានដោយផ្ទាល់របស់ជនរងគ្រោះមកឱ្យតុលាការ តាមរយៈជំនួយរបស់អង្គការ អាដហុក (ADHOC) ដែលជាអង្គការសិទ្ធិមនុស្សមួយនៅកម្ពុជា" នេះបើតាមប្រសាសន៍របស់លោកស្រី **ជា លាង** ។ "តាមរយៈចរិតដ៏ពិស្តារ និងទម្រង់បែបបទផ្តល់ព័ត៌មានដ៏ច្បាស់លាស់ យើងមានលទ្ធភាពវាយតម្លៃ និងធ្វើសកម្មភាពទៅលើព័តមាននេះ បានយ៉ាងឆាប់រហ័ស" ។ លោកបានមានប្រសាសន៍ទៀតថា សហព្រះរាជអាជ្ញាបានបន្តលើកទឹកចិត្តដល់ជនរងគ្រោះឱ្យចូលរួមជាបន្តទៅទៀត ។

ក្នុងខណៈដែលមិនមែនបទឧក្រិដ្ឋ ឬ ឧក្រដ្ឋិជនទាំងអស់សុទ្ធតែនឹងត្រូវបានចោទប្រកាន់ និងដោយសារតែចរិតភាពមានកំហិតរបស់ អ.វ.ត.ក លោកស្រី **ជា លាង** បានធានាចំពោះជនរងគ្រោះថា រាល់ពាក្យបណ្តឹងទាំងអស់នឹងត្រូវបានពិនិត្យ និងវាយតម្លៃសំរាប់ភស្តុតាងគាំទ្រសំខាន់ៗ ។ "បើគ្មានការចូលរួមរបស់ជនរងគ្រោះ និងសាក្សីទេ លទ្ធភាពរបស់តុលាការដើម្បីស្វែងរកការពិត ទាក់ទិនវិសាលភាពនៃបទឧក្រិដ្ឋ និងបុគ្គលដែលមានការទទួលខុសត្រូវ នឹងត្រូវកាត់បន្ថយយ៉ាងសំខាន់ជាមិនខាន" ។